UNIAP
UNITED NATIONS INTER-AGENCY
PROJECT ON HUMAN TRAFFICKING

# PRESS RELEASE

## បណ្ដាប្រទេសក្នុងតំបន់មេគង្គ

## កសាងសមត្ថភាពក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស

អយុធ្យា, ១៩ មិថុនា ២០០៩, តាមរបាយការណ៍របស់អង្គការសហប្រជាជាតិបានប៉ាន់ប្រមាណថាមនុស្ស ប្រមាណ២,៥លាន នាក់ត្រូវគេជួញដូរពាសពេញពិភពលោក ភាគច្រើនក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ហើយ ជនប្រព្រឹត្តល្មើសរកប្រាក់ចំណូលពីអំពើខុសច្បាប់នេះប្រមាណ ៣១ ពាន់លាន ដុល្លាអាមេរិក។ តំណាងមកពី ប្រទេសទាំង ៦ ក្នុងតំបន់ទន្លេមេគង្គបានជួបជុំគ្នារយៈពេលមួយសប្ដាហ៍ទទួលការបណ្ដុះបណ្ដាលនៅ អយុធ្យា ប្រទេស ថៃ ដើម្បីរួមគ្នាក្នុងការឆ្លើយតបនឹងអំពើជួញដូរមនុស្សដែលជាឧក្រិដ្ឋកម្មឆ្លងដែននេះ។

វគ្គបណ្ដុះបណ្ដាលថ្នាក់តំបន់នេះទទួលបានការចូលរួមពីមន្ត្រីអនុវត្តច្បាប់ពីរដ្ឋាភិបាលមន្ត្រីយុត្តិធម៌ តំណាងអង្គការ មិនមែនរដ្ឋាភិបាល ភ្នាក់ងារគាំពារជនរងគ្រោះ ក្រោមគំនិតផ្តួចផ្តើមសម្របសម្រួលរបស់ មន្ត្រីក្នុងតំបន់ ក្នុងការ ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស (ខមមីត)។ ខមមីត ដឹកនាំដោយរដ្ឋាភិបាល រាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិប្បប្រជាមានិតគេយ្យឡាវ សហភាពមីយ៉ាន់ម៉ា រាជា-ណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចងជាសម្ព័ន្ធភាពដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើនេះ។ គម្រោងអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (UNIAP) ដើរតួជាលេខាធិការ ក្នុងដំណើរការរបស់ ខមមីត ហើយទទួលការគាំទ្រយ៉ាងទូលំទូលាយពី អន្តរទីភ្នាក់ងារដែលជាដៃគូរ ជាអាទិ៍ អង្គការទេសន្តប្រវេសន៍អន្តរជាតិ IOM អង្គការពលកម្មអន្តរជាតិ ILO អង្គការទស្សនពិភពលោក WV មូលនិធិកុមារអង្គការសហប្រជាជាតិ UNICEF ធនាគារអភិវឌ្ឍអាស៊ី ADB គម្រោងប្រយុទ្ធប្រឆាំងការជួញដូរ មនុស្សក្នុងតំបន់អាស៊ី ឧបត្ថម្ភដោយថវិកាដោយរដ្ឋាភិបាល អូស្ត្រាលី ARTIP។

ក្នុងឆ្នាំ ២០០៤ ប្រទេសក្នុងតំបន់បានចុះហត្ថលេខាលើអនុស្សារណយោគយល់គ្នាជាប្រវត្តិសាស្ត្រ ដោយធានា ឱ្យបាននូវសាមគ្គីភាព និងសកម្មភាពប្រកបដោយនិរន្តរភាព និងប្ដេជ្ញាប្រយុទ្ធប្រឆាំងនឹងអំពើ ជួញដូរមនុស្ស ឱ្យចំគោលដៅ។ នេះជាកិច្ចព្រមព្រៀងតែមួយគត់លើពិភពលោកលើបញ្ហានេះ។ វគ្គបណ្ដុះបណ្ដាល



**UNIAP Regional Management Office | www.no-trafficking.org**
United Nations Building 7th floor | Block B Rajdamnern Nok Ave. | Bangkok 10200
Tel: +66-2-288-2213 | Fax: +66-2-280-0268

ថ្នាក់តំបន់នេះជាផ្នែកមួយដ៏សំខាន់ក្នុងការប្តេជ្ញាចិត្ត ពង្រឹងសមត្ថភាពដើម្បីកំណត់ តាមដានបទឧក្រិដ្ឋ និងជនល្មើសពាក់ព័ន្ធនឹងអំពើជួញដូរ និងការកេងប្រវ័ញ្ច។ ពិនិត្យ និងផ្តល់កិច្ចគាំពារដល់ជនរងគ្រោះ កំណត់ និងកាត់បន្ថយកត្តាងាយរងគ្រោះ និងពង្រឹងប្រព័ន្ធកិច្ចសហប្រតិបត្តិការតាមព្រំប្រទល់ដែន។

សិក្ខាកាមមួយចំនួនបានបង្ហាញទស្សនៈ និងគំនិតរបស់ពួកគេថា :

"អំពើជួញដូរមនុស្សជាឧក្រិដ្ឋកម្មឆ្លងដែនទាមទារឱ្យមានការសកម្មភាព និងពិភាក្សាជាអន្តរជាតិ" មន្ត្រីរដ្ឋាភិបាលចិនចូលរួមវគ្គនេះនិយាយ។ "វាអាចធ្វើទៅបានតាមរយៈការជួបប្រជុំសមភាគីពីប្រទេសក្នុងតំបន់ដើម្បីចែករំលែកព័ត៌មានដែលយើងត្រូវការក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើនេះក្នុងតំបន់របស់យើង។"

វ.ទោ ចាក់វ៉ាន់ ប៊ុមី មកពីនាយកដ្ឋានស៊ើបអង្កេតពិសេស (DSI) របស់ក្រសួងយុត្តិធម៌ថៃបានសង្កត់ធ្ងន់ពីសារប្រយោជន៍ក្នុងការចូលរួមពីបណ្តាស្ថាប័នផ្សេងៗគ្នាដើម្បីធ្វើការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ថា : "ក្នុងប្រទេសថៃ ការស៊ើបអង្កេត និងការបង្ក្រាបទៅលើជនសង្ស័យថាប្រព្រឹត្តអំពើជួញដូរមនុស្ស ជាទំនួលខុសត្រូវរបស់នគរបាល។ ផ្ទុយទៅវិញយើងតែងតែទាក់ទងទៅមន្ត្រីសង្គមកិច្ច និងតំណាងអង្គការមិនមែនរដ្ឋាភិបាល ព្រោះថាពួកគេអាចចែករំលែកព័ត៌មានសំខាន់ៗ និងជំនាញរបស់គេដល់ នគរបាលក្នុងការធ្វើប្រតិបត្តិការ"

លោក ឈួន វិបុល មកពីអង្គការលីកាដូ LICADHO ជាអង្គការមិនមែនរដ្ឋាភិបាលសិទ្ធិមនុស្សកម្ពុជាមានមតិស្របគ្នាដែរថា: "អង្គការមិនមែនរដ្ឋាភិបាល និងក្រុមការងារជួយសហគមន៍ត្រូវតែរួមចំណែកក្នុងដំណើរការប្រយុទ្ធប្រឆាំងនេះដែរ។" គាត់បន្ថែមទៀតថា "អង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីសង្គមកិច្ចអាចប្រមូលព័ត៌មានសំខាន់ៗនៅឯមូលដ្ឋាន ដូច្នេះយើងអាចដឹងច្បាស់ពីរឿងរ៉ាវនោះ។ ព័ត៌មាននេះមានសារប្រយោជន៍ដើម្បីយល់ដឹងពីភាពងាយរងគ្រោះ និងរកវិធីសាស្រ្តល្អៗសម្រាប់ផ្តល់កិច្ចគាំពារដល់ជនរងគ្រោះ។"

លោកស្រី ណាក់ អេ អេ ជី នាយិការរងតុលាការកំពូលមកពីសហព័ន្ធមីយ៉ាន់ម៉ា បានបញ្ជាក់ការពេញចិត្តពេញថ្លើមចំពោះវគ្គបណ្តុះបណ្តាលនេះ។ "យើងចង់ឃើញជនល្មើសប្រព្រឹត្តអំពើជួញដូរមនុស្សត្រូវបាន ផ្តន្ទាទោសដាក់ពន្ធនាគារ" គាត់បន្ថែមទៀតថា : "ជនជាតិភូមាត្រូវបានគេជួញដូរកាត់តាមព្រំដែន ប្រទេសជាប់ព្រំប្រទល់គ្នា។ ប្រសិនបើគ្មានកិច្ចសហប្រតិបត្តិការ និងយល់ដឹងច្បាស់លាស់ពីប្រព័ន្ធនីតិវិធី ជាមួយបណ្តាប្រទេសទាំងនោះទេ តើយើងអាចផ្តន្ទាទោសជនប្រព្រឹត្តិអំពើល្មើសដែលគួរឱ្យស្អប់ខ្ពើមនេះ ដោយរបៀបណា?"

វរសេនីយ៍ ត្រាន់ ឌិញ ហួន ប្រធានការិយាល័យប្រឆាំងអំពើជួញដូរមនុស្សនៃ ក្រសួងសន្តិសុខ សាធារណៈវៀតណាមបានលើកឡើងពីភាពងាយរងគ្រោះអំពើជួញដូរមនុស្សដែលកើតឡើងចំពេលមាន វិបត្តិហិរញ្ញវត្ថុ ពិភព-
២

លោកអាចបណ្តាលឱ្យសហគមន៏ និងគ្រួសារងាយធ្លាក់ចូលទៅក្នុងគ្រោះថ្នាក់នេះ។ “នៅប្រទេសវៀតណាម និងប្រទេសដទៃទៀតនៅក្នុងតំបន់ មានរោងចក្ររាប់រយត្រូវបិទតាំងពីប្រាំមួយខែមុនមកម្លេះ ហើយពលកររាប់ពាន់នាក់ត្រូវបានសម្រាកពីការងារ។ ក្នុងចំណោមពលករទាំងនេះភាគច្រើនជាពលករចំណាកស្រុក ហើយឥឡូវនេះត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គេវិញ។ យើងត្រូវការធ្វើការផ្តល់ កិច្ចគាំពារឱ្យអស់លទ្ធភាពរបស់យើងចំពោះពួកគេ និងគ្រួសាររបស់គេពីភាពងាយរងគ្រោះធ្ងន់ធ្ងរពីការកេងប្រវ័ញ្ចក្នុងខណៈដែលរោងចក្រទាំងនោះកំពុងត្រដរបន្តដំណើរការក្នុងស្ថានភាពលំបាកនេះ។”

លោក វ៉ាន់ណាឡេត ចាន់ថាវង្ស មកពីក្រសួងការងារ និងសុខុមាលភាពសង្គម នៃសាធារណរដ្ឋប្រជាមានិតប្រជាធិប្បតេយ្យឡាវ បានបន្ថែមថា ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស យើងត្រូវផ្តល់ឱកាស និងកែលម្អជីវភាពគួរតែធ្វើឡើងក្នុងស្រុក។ “ឡាវជាប្រទេសប្រភព មានន័យថាប្រជាពលរដ្ឋឡាវត្រូវបានគេជួញដូរទៅកាន់ប្រទេសឯទៀត។ ការបង្កើនការងារក្នុងស្រុកធ្វើឱ្យការចាកចេញទៅធ្វើការងារក្រៅស្រុក ថយចុះ។”

ការជួញដូរមនុស្សជាបញ្ហាស្មុគស្មាញបំផុតក្នុងតំបន់នេះដោយសារកត្តាជាច្រើន។ កត្តាសំខាន់មួយក្នុងនោះគឺ កង្វះខាតការសម្របសម្រួលរវាងប្រទេស និងកង្វះខាតចំណេះដឹងក្នុងជួរមន្ត្រីរដ្ឋាភិបាលអំពីរបៀបប្រយុទ្ធប្រឆាំងនឹងអំពើនេះ។ ប្រសិនបើគ្មានកិច្ចសហការអន្តរាគមន៏ពី ខមមីត ជនល្មើសជួញដូរមនុស្សនឹងបន្ត ប្រព្រឹត្តដើម្បីផល-ប្រយោជន៏ដ៏សម្បើមលើខ្នងអ្នករងគ្រោះរាប់លាននាក់ក្នុងកណ្តាប់ដៃរបស់គេ។

សម្រាប់ព័ត៏មានបន្ថែមសូមទាក់ទង :

ជាភាសាអង់គ្លេស :
Ms. Dominique Larsimont, UNIAP
dominique.larsimont@undp.org
+66 2 288 2673 (Thailand)

ជាភាសាខ្មែរ :
Mr. Huot Vichheka, UNIAP
vichheka.huot@undp.org
+855 23 211 240 ext.334 (Cambodia)

ជាភាសាឡាវ :
Mr. Phimmasone Thongphataysack, UNIAP
phimmasone.thongphataysack@undp.org
+856 21 267 792 (Lao PDR)

ជាភាសាថៃ :
Ms. Suparnee Pongruengphant, UNIAP
suparnee.pongruengphant@un.or.th
+66 2 288 1746 (Thailand)

ជាភាសាវៀតណាម :
Ms. Nguyen Thi Cam Thuy, UNIAP
nguyen.thi.cam.thuy@un.org.vn
+84 43 942 6511 (Vietnam)

ជាភាសាភូមា :
Mr. Aung Ye Htut, UNIAP
ayhtut.uniapmm@undp.org
+95 1 254 852/3 (Myanmar)

ជាភាសាចិន :
Ms. He Yuxiao, UNIAP
yunxiao.he@public.un.org.cn
+86 10 6420 1827 (China)